# ការធានារ៉ាប់រងកុមារទាំងអស់

## ដំណឹងល្អ!

កុមារគ្រប់រូបសមនឹងទទួលបានការថែទាំសុខភាព។
ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2022, កុមារ
(អាយុក្រោម 19 ឆ្នាំ) ដែលមានប្រាក់ចំណូលមិនលើស
ពីដែនកំណត់ទាំងអស់ដែលរស់នៅ Rhode Island
អាចចុះឈ្មោះក្នុងការធានារ៉ាប់រងសុខភាព
RIte Care (Medicaid) ដោយមិនគិតស្ថានភាព
អន្តោប្រវេសន៍រួមទាំងកុមារដែលគ្មានសិទ្ធិរស់នៅ
និងអ្នកទទួល DACA ផងដែរ។

ការចុះឈ្មោះក្នុងការធានារ៉ាប់រង RIte Care
មិនមានផលប៉ះពាល់លើស្ថានភាពអន្តោប្រវេសន៍របស់អ្នក
ឬកម្មវិធីអន្តោប្រវេសន៍សម្រាប់កូនរបស់អ្នក
ឬនរណាម្នាក់ក្នុងគ្រួសាររបស់អ្នកទេ។

ការធានារ៉ាប់រងរបស់ RIte Care រួមមាន
ការទៅជួបគ្រូពេទ្យ, ការពិនិត្យសុខភាព
ប្រចាំឆ្នាំរបស់សាលា, វេជ្ជបញ្ជាទិញថ្នាំ,
ការថែទាំសុខភាពផ្លូវចិត្ត, ថែទាំនៅមន្ទីរពេទ្យ,
និងច្រើនទៀត.

## 3 វិធីដើម្បីដាក់ពាក្យសុំ

**1**

ដាក់ពាក្យតាមទូរស័ព្ទនៅ Health Source RI មជ្ឈមណ្ឌលទំនាក់ទំនង

ទូរស័ព្ទ 1-855-840-4774
(សម្រាប់ភាសា អេស្ប៉ាញ សូមចុចលេខ2។
មានអ្នកបកប្រែសម្រាប់ភាសាផ្សេងទៀត។
សូមចុចលេខ 1
ហើយនិយាយភាសាណាដែលអ្នកត្រូវការ។)

**2**

ដាក់ពាក្យជាមួយអ្នកដឹកនាំផ្លូវ
នៅក្នុងសហគមន៍របស់អ្នក
ទូរស័ព្ទ 2-1-1
អ្នកដឹកនាំផ្លូវនិយាយច្រើនភាសា

**3**

ដាក់ពាក្យតាម អនឡាញ -
ចូលទៅកាន់គេហទំព័រ
Healthyrhode.ri.gov

SCAN ME